# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អគ្គសញ្ញាលាបថ្វាសនៅបឹងទំពុន
# ថ្ងៃទី០២ កក្កដា ២០១៧

អត្ថបទទី១៖២ពង្សា ៤,៨-១១.១៤-១៦
អត្ថបទទី២៖រម ៦,៣-៤.៨-១១
ដំណឹងល្អ៖មថ ១០,៣៧-៤២

បងប្អូនជាទីស្រឡាញ់!

ប៉ុន្មានថ្ងៃមុន យើងគោរពសន្តយ៉ូហានបាទីស្ទ ដែលជាព្យាការីចុងក្រោយ ជាបងជីដូនមួយរបស់ព្រះយេស៊ូ។ គាត់មានឪពុកម្ដាយចាស់ជរាហើយ នៅពេលម្ដាយរបស់លោកដែលជាស្រ្តីអាបានទទួលដំណឹងថាមានផ្ទៃពោះហើយ ឪពុករបស់លោកយ៉ូហានបាទីស្ទមិនអាចទទួលស្គាល់គាត់ក៏ក្លាចជាមនុស្សគរនិយាយមិនបាន។ នៅពេលលោកយ៉ូហានបាទីស្ទកើតមក គេដាក់ឈ្មោះថាសាការីដូចឪពុកគាត់តែម្ដាយគាត់មិនព្រមយកឈ្មោះនេះទេ ក៏សួរប្ដីក៏គាត់ឆ្លើយថាឈ្មោះយ៉ូហានក្រោយមកលោកសាការីក៏និយាយបានដូចដើមវិញ។ នៅពេលអ្នកជិតខាងគេដឹងអំពីរឿងលោកយ៉ូហានបាទីស្ទ នៅពេលលោកមានអាយុមួយថ្ងៃគេសួរថា **តើកូននេះនៅថ្ងៃអនាគតកូននេះនឹងទៅជាយ៉ាងណា?** ថ្ងៃនេះខ្ញុំចង់សួរដល់ប្អូនៗដែលនឹងទទួលអគ្គសញ្ញាលាបថ្វាសបន្តិចទៀត តើទៅថ្ងៃក្រោយយើងទៅជាមនុស្សយ៉ាងណា? តើព្រះជាម្ចាស់មានគម្រោងការណ៍អ្វីខ្លះសម្រាប់ជីវិតខ្ញុំ? នៅក្នុងគម្ពីរដំណឹងល្អ គម្រោងការណ៍របស់ព្រះយេស៊ូសម្រាប់យើងមិនធម្មតាទេ **"នៅពេលអ្នកណាស្រឡាញ់ឪពុកម្ដាយខ្លាំងជាស្រឡាញ់ខ្ញុំ អ្នកនោះមិនសមធ្វើជាសាវ័ករបស់ខ្ញុំឡើយ អ្នកដែលស្រឡាញ់កូនប្រុសកូនស្រីខ្លាំងជាស្រឡាញ់ខ្ញុំ ក៏មិនសមធ្វើជាសាវ័ករបស់ខ្ញុំដែរ"**។ ពេលយើងស្ដាប់ហើយ យើងគិតថាពិបាកចូលនៅក្នុងគម្រោងការណ៍របស់ព្រះជាម្ចាស់ ជាមូលហេតុមានអ្នកខ្លះនិយាយថាសាសនាយេស៊ូណែនាំមិនឲ្យស្រឡាញ់ឪពុកម្ដាយ ណែនាំឲ្យកូនទៅជាកូនអកត្តញ្ញូ។ ពេលយើងអានគម្ពីរនេះ ហើយមិនគិតវែងឆ្ងាយណែនាំឲ្យយើងយល់ថា ឪពុកម្ដាយមិនសំខាន់ កូនប្រុសកូនស្រីមិនសំខាន់ យើងត្រូវតែស្រឡាញ់ព្រះយេស៊ូដើម្បីធ្វើជាសាវ័ករបស់ព្រះអង្គ។ ប៉ុន្តែបើយើងគិត ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលមួយយ៉ាងសំខាន់សម្រាប់យើង ឲ្យយើងជ្រើសរើសព្រះយេស៊ូជាអាទិភាពនៅក្នុងជីវិតយើង ឥតមាននិយាយថាកុំគោរពឪពុកម្ដាយ កុំស្រឡាញ់កូនប្រុសកូនស្រី គ្រាន់តែព្រះយេស៊ូចង់ឲ្យយើងយកព្រះអង្គជាអាទិភាពនៅក្នុងជីវិតរបស់យើង។ ថ្ងៃនេះដែលមានប្អូន

ទទួលព្រះវិញ្ញាណដ៏វិសុទ្ធ អាចនិយាយថាថ្ងៃនេះប្អូនកើតសារជាថ្មីនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធតែម្តង។ ហេតុនេះហើយ យើងត្រូវតែទទួលព្រះយេស៊ូជាជីវិតរបស់យើង ដើម្បីដឹកនាំជីវិតយើងពីមួយថ្ងៃទៅមួយថ្ងៃ។ មានន័យថា ព្រះយេស៊ូបានជ្រើសរើសយើងពីថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក និងថ្ងៃនេះព្រះយេស៊ូជ្រើសរើសយើងម្តងទៀតដើម្បីប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើយើង។ ព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងអាចស្រែកថា **ឱព្រះបិតាអើយ! យើងជាបុត្រធីតារបស់ព្រះអង្គ ដោយសារយើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ**។ ថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលតែមួយសម្រាប់យើង ឲ្យយើងជ្រើសរើសយកព្រះយេស៊ូជាអាថ៌ទិភាព ដើម្បីដឹកនាំជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ។

គម្រោងការណ៍របស់ព្រះជាម្ចាស់សម្រាប់យើងគឺ យើងជាបុត្រធីតារបស់ព្រះអង្គ ហើយយើងជ្រើសយកព្រះយេស៊ូជាអាថ៌ទិភាព ដើម្បីធ្វើជាសាវ័ករបស់ព្រះគ្រីស្ត។ ឲ្យយើងទទួលស្គាល់ថា យើងមានព្រះបិតាតែមួយព្រះអង្គគត់ ដែលប្រទានជីវិត ដែលប្រទានសេចក្តីស្រឡាញ់ ដែលណែនាំឲ្យយើងមានសេចក្តីសង្ឃឹម។ យើងជ្រើសយកព្រះយេស៊ូជាអាថ៌ទិភាព ដើម្បីជ្រើសរើសអនាគតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ យើងត្រូវតែស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីបំភ្លឺយើង។ បើយើងមិនយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីបំភ្លឺយើង នោះយើងនឹងទៅតាមការណែនាំរបស់សង្គមមិនខាន។ ថ្ងៃនេះព្រះយេស៊ូណែនាំឲ្យយើងយកព្រះអង្គជាទីពឹង ជាអាថ៌ទិភាពដើម្បីដឹកនាំជីវិតរបស់យើង។ ពេលយើងស្តាប់អត្ថបទនេះបន្តទៀត យើងឃើញព្រះយេស៊ូណែនាំឲ្យយើងរស់នៅតាមរបៀបដ៏សាម័ញ្ញរបស់ព្រះអង្គ **អ្នកណាឲ្យទឹកត្រជាក់សូម្បីតែមួយកែវ ដល់អ្នកតូចតាចម្នាក់ក្នុងនាមជាសាវ័កខ្ញុំ ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យដឹងច្បាស់ថាអ្នកនោះនឹងទទួលរង្វាន់ជាមិនខាន** ព្រះយេស៊ូមិនណែនាំឲ្យយើងធ្វើអ្វីអស្ចារ្យទេ។ ព្រះយេស៊ូបានរើសពាក្យយ៉ាងច្បាស់៖

ទីមួយ សូមឲ្យទឹកត្រជាក់ មានន័យថាព្រះយេស៊ូណែនាំឲ្យយើងយកចិត្តទុកដាក់នឹងអ្នកដទៃ ឲ្យយើងយកទឹកត្រជាក់ឲ្យគេដោយដឹងថាថ្ងៃនេះក្តៅថ្ងៃនេះគេអស់កម្លាំង ដើម្បីផ្តល់កម្លាំងឲ្យគេ។ ពេលយើងជួយអ្នកដទៃដោយនាមព្រះយេស៊ូ មានន័យថាយើងយកចិត្តទុកដាក់ យើងខិតខំឆ្លើយតបនឹងសេចក្តីត្រូវការរបស់គេពិតមែន។ ទឹកត្រជាក់ណែនាំឲ្យគេកក់ក្តៅ ណែនាំឲ្យគេមានកម្លាំង ណែនាំឲ្យគេយល់ថាគេមានតម្លៃណាស់។ នៅពេលយើង

ឲ្យលុយទៅអ្នកសុំទាននៅតាមផ្លូវ ឲ្យយើងឲ្យលុយគេហើយសួរសុខទុក្ខគេ លើកទឹកចិត្តគេ ដើម្បីឲ្យគេមានកម្លាំង ដើម្បីបង្ហាញថាយើងបានយកចិត្តទុកដាក់នឹងគេ។

ទីពីរ ព្រះយេស៊ូថែមទៀតថា មិនឲ្យទូទៅគឺដល់អ្នកតូចតាចម្នាក់គឺយើងទៅរើសអ្នកដែលគ្មានអ្វីសោះ អ្នកដែលកំពុងអស់សង្ឃឹម អ្នកដែលសង្គមមើលមិនឃើញ។ អ្នកតូចតាចដែលគ្មានផ្លូវដើរ ដែលគ្មានសេចក្តីសង្ឃឹម ឲ្យយើងបើកភ្នែកថែមទៀតដើម្បីមើលឃើញអ្នកទាំងនោះ។ ខ្ញុំសប្បាយចិត្ត ដោយសារព្រះសហគមន៍បឹងទំពុននេះបានបង្កើតសាលាមួយយ៉ាងពិសេសសម្រាប់កូនក្មេង ដែលមិនអាចទៅរៀនសូត្រនៅតាមសាលាធម្មតាបាន នេះជារបៀបមួយ ដែលយើងបានបង្ហាញអំពីសេចក្តីស្រឡាញ់ចំពោះអ្នកតូចតាច។

ទីបី ក្នុងនាមជាសាវ័ករបស់ខ្ញុំ យើងជួយគេដោយសារយើងជាសាវ័ករបស់ព្រះយេស៊ូ មានន័យថាយើងដើរតាមព្រះយេស៊ូ យើងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ដូចព្រះអង្គមានព្រះបន្ទូលថា **"ចាប់ពីពេលនេះតទៅខ្ញុំលែងហៅបងប្អូនជាអ្នកបម្រើ តែបងប្អូនទៅជាមិត្តសម្លាញ់របស់ខ្ញុំវិញ"**។ ដូច្នេះ ទាំងបូណដែលទទួលអគ្គសញ្ញាលាបថ្វាសថ្ងៃនេះ និងបងប្អូនទាំងអស់គ្នាថ្ងៃនេះព្រះយេស៊ូបានជ្រើសរើសយើង ទៅជាមិត្តសម្លាញ់របស់ព្រះអង្គ ដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូ គ្រប់សកម្មភាពដែលយើងធ្វើយើងធ្វើដោយសេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះយេស៊ូ។ ខ្ញុំសង្ឃឹមថា ព្រះសហគមន៍នៅបឹងទំពុននេះទៅជាកន្លែងកណ្តាលមួយ សម្រាប់បងប្អូននៅជិតៗនេះ ដើម្បីឲ្យគេយល់ថាកន្លែងនេះជាកន្លែងមួយគេអាចរកឃើញភាពកក់ក្តៅ រកឃើញសេចក្តីសង្ឃឹម។ កុំឲ្យយើគិតតែបងប្អូនដែលជាអ្នកតូចតាច គឺយើងស្វាគមន៍ទាំងអ្នកក្រទាំងអ្នកមានដែលរកមិនឃើញផ្លូវនៅក្នុងជីវិតដើម្បីចិញ្ចឹមដួងចិត្តឲ្យមានសេចក្តីសង្ឃឹមជាថ្មី។ យើងមានលុយច្រើនយ៉ាងណាក៏សោយបើយើងគ្មានទំនាក់ទំនងជាមួយព្រះជាម្ចាស់ជីវិតរបស់យើងគ្មានអត្ថន័យ ជីវិតយើងមានសេចក្តីសង្ឃឹមនៅពេលយើងដឹងថាយើងមានព្រះជាម្ចាស់ដែលគង់នៅ ដែលណែនាំយើងជារៀងរាល់ថ្ងៃឲ្យយើងមានផ្លូវមួយយ៉ាងពិសេស គឺផ្លូវនៃជីវិតអស់កាលជានិច្ច។

ថ្ងៃនេះយើងបានទទួលបេសកកម្មមួយយ៉ាងពិសេស ដោយនាមយើងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ដោយព្រះយេស៊ូបានជ្រើសរើសយើង និងដោយយើងបានជញរើសរើសព្រះយេស៊ូជាអាថ៌ទិភាព យើងធ្វើដូចម្តេចដើម្បីឲ្យព្រះសហគមន៍របស់យើងនៅទី

នេះ ទៅជាកន្លែងមួយដើម្បីទាក់ទាញមនុស្សឲ្យគេរកឃើញជីវិត និងរកឃើញសេចក្តីសង្ឃឹមដោយសារសេចកត្ីស្រឡាញ់ដែលយើងបានចែករំលែក។ នៅមណ្ឌលនិស្សិតក៏ដូចគ្នា ឲ្យកន្លែងយើងទៅជាកន្លែងដើម្បីទទួលបងប្អូននិស្សិតដែលមកពីសាកលវិទ្យាល័យនៅជិតៗឲ្យគេចាប់អារម្មណ៍អំពីតម្លៃនៃជីវិត និងឲ្យគេមានសំនួរថា **តើនៅថ្ងៃអនាគតខ្ញុំអាចធ្វើអ្វីខ្លះបាន?** មិនមែនសម្រាប់ខ្ញុំប៉ុន្តែសម្រាប់បងប្អូនឯទៀតៗ។ បើគ្មានសេចក្តីសង្ឃឹមឥតចិត្តបម្រើ បើគ្មានចិត្តបម្រើឥតមានសុខសន្តិភាពនៅក្នុងពិភពលោក។ ពាក្យរបស់សន្តី តេរេសាថា សេចក្តីសង្ឃឹមណែនាំឲ្យយើងបម្រើ ការបម្រើណែនាំឲ្យយើងរកឃើញសុខសន្តិភាពនៅក្នុងពិភពលោក។

ថ្ងៃនេះយើងសប្បាយចិត្ត ដោយសារព្រះយេស៊ូមានព្រះបន្ទូលតែមួយ គឺឲ្យជ្រើសរើសព្រះយេស៊ូមុនគេបង្អស់ដើម្បីដឹកនាំជីវិតរបស់យើង យើងបន្តស្រឡាញ់ឪពុកម្តាយយើង យើងបន្តស្រឡាញ់កូនប្រុសកូនស្រី ដើម្បីបង្កើតព្រះសហាគមន៍មួយដែលជាក្រុមគ្រួសាររបស់ព្រះគ្រីស្ត។ អាម៉ែន៕